ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ធំ**

-សំណុំរឿងក្តីលេខ:៥១
ចុះថ្ងៃទី២១ ខែ០១ ឆ្នាំ២០២០
-សញ្ញាណនៃរឿងក្តី: **សុំផ្តាច់អនីតិសង្វាស់**
-សាលក្រមរដ្ឋប្បវេណីលេខ: **២០ ( ក )**
ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

**គាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ធំ**
**ចេញសាលក្រមដែល មានខ្លឹមសារដូចតទៅ**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០
-ប្រកាសសាលក្រម ជាសាធារណ: នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ។

**ចៅក្រម**

- លោក [redacted] ចៅក្រម និង ជាប្រធានសាលាដំបូងខេត្តកំពង់ធំ ។

**ក្រឡាបញ្ជី**

- លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ ។

-**ដើមចោទ** ឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ [redacted] (វត្តមាន) មានមេធាវីតំណាងដោយអាណត្តិឈ្មោះ [redacted] អត្តលេខ: ១៨០៩ T និង មេធាវី [redacted] អត្តលេខ: ៥៥៩ ជាមេធាវីដើមចោទ។

-**ចុងចម្លើយ** ឈ្មោះ [redacted] ប៊ុនជន ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ មានទី [redacted] (វត្តមាន) ។

**អង្គហេតុ និងចំនុចវិវាទ**

**១./ការទាមទារៈក្នុងរឿងនេះដើមចោទប្តឹងសុំទាមទារឲ្យតុលាការចេញសាលក្រមដូចខាងក្រោម:**

១. ប្តឹងសុំផ្តាច់អនីតិសង្វាស់ពីប្តី ។

២. សុំគ្រប់គ្រងកូនម្នាក់ឈ្មោះ [redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និង ឈ្មោះ [redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ ២០០៧ ។

៣.ទ្រព្យសម្បត្តិរួមមានដីទំហំ ៨ម គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទ មានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ។

៤- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២./ ការពន្យល់គ្រួសៗអំពីអត្ថន័យរឿងក្តី**

ដើមចោទមិនអាចផ្សះផ្សារជាមួយចុងចម្លើយជាប្តីប្រពន្ធវិញទេគឺ១.ប្តឹងសុំផ្តាច់អនីតិសង្វាស់ពីប្តី, ២.សុំគ្រប់គ្រងកូនពីរនាក់ឈ្មោះ [redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ ២០០៧ , ៣.ទ្រព្យសម្បត្តិរួមមានដីទំហំ៨ម គុណ១២ម សង់លើដីកេរ្តិ៍ម្តាយដើមចោទមានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ,៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

Scanned with CamScanner

នាងខ្ញុំបានរៀបការជាមួយចុងចម្លើយជាប្តីប្រពន្ធតាំងពីឆ្នាំ២០០១ មកម្ល៉េះតាមប្រពៃណី និង មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ទេ ។ ចាប់តាំងពីពេលរៀបការរួចមកជាមួយចុងចម្លើយ កូនពីរនាក់ឈ្មោះ[redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និង ឈ្មោះ [redacted] **ច័ន្ទបរម៉ី** ភេទស្រី កើតឆ្នាំ ២០០៧ មិនទាមទារអាហាកាតព្វកិច្ចចិញ្ចឹមកូនពីចុងចម្លើយនោះទេ,៣.ទ្រព្យសម្បត្តិរួមមានដីទំហំ **៨ម** គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទ មានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ធ្វើនៅឆ្នាំ២០១៣ នាងខ្ញុំសុំគ្រប់គ្រងព្រោះនាងខ្ញុំជាអ្នករកចំណូល និងចំណាយតែម្នាក់ឯង ដោយភាគីចុងចម្លើយមិនបានចេញចំណាយអ្វីទាំងអស់ ការធ្វើផ្ទះនោះគឺនាងខ្ញុំជួលជាងជាចុងចម្លើយមកធ្វើផ្ទះ ហើយនាងខ្ញុំបានឱ្យលុយគាត់៣ម៉ឺនរៀល ក្នុងមួយថ្ងៃសម្រាប់ជួលចុងចម្លើយជាលុយរបស់នាងខ្ញុំតែម្នាក់ឯក មិនមែនជាលុយរបស់គាត់ទេ ចុងចម្លើយតែងតែលេងល្បែងបំផ្លាញទ្រព្យសម្បត្តិអស់យ៉ាងច្រើន និងមានបំណងដុតផ្ទះចោល និង មានជំពាក់បំណុលធនាគារចំនួន ៣២០០០$ (បីម៉ឺនពីរពាន់) ដុល្លាអាមេរិក ។

មូលហេតុដែលនាងខ្ញុំ ដាក់ពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយនេះ គឺដោយសារតែរស់នៅជាមួយគ្នាជាប្តីប្រពន្ធចេះឈ្លោះប្រកែកគ្នា ជាញឹកញាប់ធ្វើឱ្យគ្រួសារមិនមានសុភមង្គល ហើយនាងខ្ញុំនិងចុងចម្លើយរស់នៅមិននិយាយរកគ្នានោះទេ ហើយចុងចម្លើយមិនដែលផ្គត់ផ្គង់ចិញ្ចឹមនាងកូន និងគ្រួសារនោះទេ ធ្វើឱ្យនាងខ្ញុំអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធតទៅទៀត ទើបនាងខ្ញុំឱ្យតុលាការសម្រេចចេញសាលក្រមប្តឹងសុំផ្តាច់អនីតិសង្វាស់ពីប្តីដូចខាងលើ ។

### ៣./ **ការអះអាងរបស់ភាគី នាពេលទាញហេតុផលដោយផ្ទាល់មាត់**

**-ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍** ថានាងខ្ញុំមិនអាចផ្សះផ្សារជាមួយចុងចម្លើយជាប្តីប្រពន្ធវិញទេគឺ ១. ប្តឹងសុំអនីតិសង្វាស់ពីប្តី ,២. សុំគ្រប់គ្រងកូនពីរនាក់ឈ្មោះ [redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] **ច័ន្ទបរម៉ី** ភេទស្រី កើតឆ្នាំ ២០០៧ , ៣.ទ្រព្យសម្បត្តិរួមមានដីទំហំ **៨ម** គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទ មានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ,៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

នាងខ្ញុំបានរៀបការជាមួយចុងចម្លើយជាប្តីប្រពន្ធតាំងពីឆ្នាំ២០០១ មកម្ល៉េះតាមប្រពៃណី និង មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ទេ ។ ចាប់តាំងពីពេលរៀបការរួចមកជាមួយចុងចម្លើយ កូនពីរនាក់ឈ្មោះ[redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និង ឈ្មោះ[redacted] **ច័ន្ទបរម៉ី** ភេទស្រី កើតឆ្នាំ ២០០៧ មិនទាមទារអាហាកាតព្វកិច្ចចិញ្ចឹមកូនពីចុងចម្លើយនោះទេ,៣.ទ្រព្យសម្បត្តិរួមមានដីទំហំ **៨ម** គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទ មានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ធ្វើនៅឆ្នាំ២០១៣ នាងខ្ញុំសុំគ្រប់គ្រងព្រោះនាងខ្ញុំជាអ្នករកចំណូល និងចំណាយតែម្នាក់ឯង ដោយភាគីចុងចម្លើយមិនបានចេញចំណាយអ្វីទាំងអស់ ការធ្វើផ្ទះនោះគឺនាងខ្ញុំជួលជាងជាចុងចម្លើយមកធ្វើផ្ទះ ហើយនាងខ្ញុំបានឱ្យលុយគាត់៣ម៉ឺនរៀល ក្នុងមួយថ្ងៃសម្រាប់ជួលចុងចម្លើយជាលុយរបស់នាងខ្ញុំតែម្នាក់ឯក មិនមែនជាលុយរបស់គាត់ទេ ចុងចម្លើយតែងតែលេងល្បែងបំផ្លាញទ្រព្យ

Scanned with CamScanner

សម្បត្តិអស់យ៉ាងច្រើន និងមានបំណងដុតផ្ទះចោល និង មានជំពាក់បំណុលធនាគារចំនួន ៣២០០០$ (បីម៉ឺនពីរពាន់) ដុល្លាអាមេរិក ។

មូលហេតុដែលនាងខ្ញុំ ដាក់ពាក្យបណ្ដឹងសុំលែងលះពីចុងចម្លើយនេះ គឺដោយសារតែរស់នៅជាមួយគ្នាជាប្ដីប្រពន្ធចេះឈ្លោះប្រកែកគ្នា ជាញឹកញាប់ធ្វើឲ្យគ្រួសារមិនមានសុភមង្គល ហើយនាងខ្ញុំនិងចុងចម្លើយរស់នៅមិននិយាយរកគ្នានោះទេ ហើយចុងចម្លើយមិនដែលផ្គត់ផ្គង់ចិញ្ចឹមនាងកូន និងគ្រួសារនោះទេ ធ្វើឲ្យនាងខ្ញុំអស់មនោសញ្ចេតនានឹងគ្នាជាប្ដីប្រពន្ធតទៅទៀត ទើបនាងខ្ញុំឲ្យតុលាការសម្រេចចេញសាលក្រមប្ដឹងសុំផ្ដាច់អនីតិសង្វាស់ពីប្ដីដូចខាងលើ ។

**-ចុងចម្លើយបានធ្វើសេចក្ដីថ្លែការណ៏** តបថា ចំពោះការប្ដឹងសុំផ្ដាច់អនីតិសង្វាស់របស់ដើមចោទនោះ ខ្ញុំបាទមិនឯកភាពព្រមតាមការសុំរបស់ដើមចោទទេ ។ ព្រោះកន្លងមកខ្ញុំបាទមិនមានកំហុសទេ, ចំពោះការសុំគ្រប់គ្រងកូនពីរនាក់ឈ្មោះ [redacted] **ផូរអ៊័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ ២០០៧ មិនអាហាកាតព្វកិច្ច ព្រោះខ្ញុំបាទសុំគ្រប់គ្រងកូនដែរ ,៣.ទ្រព្យសម្បត្តិរួមមានដីទំហំ ៨ម គុណ **១២ម** សង់លើដីកេរ្តិ៍ម្ដាយដើមចោទមានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ខ្ញុំបាទមិនឯកភាពតាមដើមចោទគឺខ្ញុំបាទសុំគ្រប់គ្រងដែរសុំបែងចែកជាពីរចំណែកស្មើគ្នាព្រោះ ជាកម្លាំងញើញឈាមដែលខ្ញុំបាទខិតខំបានធ្វើដោយផ្ទាល់ខ្លួនខ្លួនទទួលស្គាល់ថាដីដែលសង់ផ្ទះនោះម្ដាយក្មេងនោះពិតប្រាកដមែន និងចំពោះបំណុលខ្ញុំបាទទទួលស្គាល់ថា មានជំពាក់គេ ចំនួន៣២០០០$ (បីម៉ឺនពីរពាន់) ជំពាក់ធនាគារអេស៊ីលីដាមានជំពាក់គ្នាបីនាក់ គឺសុំឲ្យតុលាការស្មើគ្នា ។

**-ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៏** ថានាងខ្ញុំ នាងខ្ញុំមានការជំពាក់ធានាគារចំនួន **៣២០០០$** (បីម៉ឺនពីរពាន់) ជំពាក់ធនាគារអេស៊ីលីដា ដោយយកលុយធ្វើផ្ទះនេះអស់ហើយនាងខ្ញុំមិនទាមទារ គឺសុំគ្រប់គ្រងផ្ទះនេះតែម្នាក់និងទទួលខុសត្រូវលើបំណុលតែម្នាក់ឯង ចំពោះការសុំគ្រប់គ្រងកូនទាំងពីរនាក់ និងសុំឲ្យតុលាការសម្រេចតាមការស្នើសុំខាងលើ ។

**-កូនស្រីពីរនាក់** ឈ្មោះ [redacted] **ផូរអ៊័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ ២០០៧ បានឆ្លើយបំភ្លឺថា ពួកខ្លួនចង់ទៅរស់នៅខាងម្ដាយ ជាដើមចោទ ។

**-សាក្សី** ឈ្មោះ [redacted] **ចរិយា** ភេទស្រី អាយុ......ឆ្នាំ បានឆ្លើយបំភ្លឺថា ចុងចម្លើយការធ្វើផ្ទះ គឺដើមចោទជាអ្នកប្រគល់លុយឲ្យចុងចម្លើយជាអ្នកធ្វើផ្ទះទាំងអស់ ចុងចម្លើយមិនមានលុយទេ ។

**-សាក្សីឈ្មោះ** [redacted] **ជា** ភេទប្រុស អាយុ ....ឆ្នាំ បានឆ្លើយបំភ្លឺថា ចុងចម្លើយការធ្វើផ្ទះ គឺដើមចោទជាអ្នកប្រគល់លុយឲ្យចុងចម្លើយជាអ្នកធ្វើផ្ទះទាំងអស់ ចុងចម្លើយមិនមានលុយទេ គឺគ្រាន់តែស៊ីឈ្នួលប្រពន្ធគាត់តែប៉ុណ្ណោះ ។

**-ចុងចម្លើយបានធ្វើសេចក្ដីថ្លែការណ៏** តបថា ចំពោះការសុំគ្រប់គ្រងផ្ទះខ្ញុំបាទមិនឯកភាពទេ ,ហើយបំណុលជំពាក់ធនាគារ ៣២០០០$ (បីម៉ឺន) ដុល្លាអាមេរិក នោះខ្ញុំបាទបានផ្ដិតមេដៃ ទទួលស្គាល់តែលុយនោះខាងដើម

ចោទខ្ចីឱ្យម្តាយក្មេកខ្លួននោះទេ, ចំពោះការសុំគ្រប់កូនទាំងនេះ ហើយកូនសុំរស់នៅខាងម្តាយនោះខ្ញុំមិនឯកភាពទេ សុំគ្រប់គ្រងម្នាក់ដែរ ។

**-មេធាវីតំណាងដោយអាណត្តិដើមចោទធ្វើសេចក្តីសន្និដ្ឋាន** ថាកូនក្តី នាងខ្ញុំមានការជំពាក់ធានគារចំនួន **៣២០០០$** (បីម៉ឺនពីរពាន់) ជំពាក់ធនាគារអេស៊ីលីដា ដោយយកលុយធ្វើផ្ទះនេះអស់ គឺកូនក្តីខ្ញុំបាទសុំគ្រប់គ្រងផ្ទះ និងទទួលខុសត្រូវលើបំណុលតែម្នាក់ឯង ចំពោះការសុំគ្រប់គ្រងកូនទាំងពីរនាក់កូនស្រីទាំងពីរបានឆ្លើយថា រស់នៅខាងម្តាយ និងសុំឱ្យតុលាការសម្រេចតាមការស្នើសុំរបស់កូនក្តីខ្ញុំបាទខាងខាងលើនេះ ។

## ចំនុចវិវាទ និងចំនុចគ្មានវិវាទ

ចំពោះរឿងនេះ មានគ្រប់ចំនុចវិវាទដូចការប្តឹងទាមទាររបស់ដើមចោទ ។

**-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍ របស់ដើមចោទ និងចុងចម្លើយ**

**-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិដើមចោទ**

**-ក្រោយពីបានឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់**

**-ក្រោយពីបានពិនិត្យឯកសារ និង ភស្តុតាង នៃសំណុំរឿងរួចហើយ**

**-ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ ។**

## សំអាងហេតុ និងការយល់ឃើញ

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ: ៣៤៨ ចុះថ្ងៃទី២៤ ខែ០៧ ឆ្នាំ២០១៩ ។

**-បានឃើញ:** កំណត់ហេតុស្តីពីនីតិវិធីត្រៀមទាញហេតុផល ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ។

**-បានឃើញ:** សំបុត្រអាពាហ៍ពិពាហ៍លេខ: ៤០ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ។

**-បានឃើញ:** វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 06070308-1511 ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩

**-បានឃើញ:** លិខិតបញ្ជាក់ប្រវត្តិដីធ្លីចំនួនលេខ: **២៩៥១** ចុះថ្ងៃទី១៩ ខែ១០ ឆ្នាំ២០១៨ ។

**-បានឃើញ:** លិខិតបញ្ជាក់ប្រវត្តិដីធ្លីចំនួនលេខ: **២២៤៣** ចុះថ្ងៃទី២១ ខែ០៨ ឆ្នាំ២០១៨ ។

**-បានឃើញ:** លិខិតបញ្ជាក់ប្រវត្តិដីធ្លីចំនួនលេខ: **១៩៧១** ចុះថ្ងៃទី១៩ ខែ០៦ ឆ្នាំ២០១៩ ។

**-បានឃើញ:** កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី២៧ ខែ០៨ ឆ្នាំ២០១៨ ។

**-បានឃើញ:** កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

**-យល់ឃើញថា** តាមដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ ថាខ្លួនមិនអាចផ្សះផ្សារជាមួយចុងចម្លើយជាប្តីប្រពន្ធវិញទេគឺ១.ប្តឹងសុំអនីតិសង្វាស់ពីប្តី,២.សុំគ្រប់គ្រងកូនពីរនាក់ឈ្មោះ[redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ[redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ ២០០៧,៣.ទ្រព្យសម្បត្តិរួមមានដីទំហំ **៨ម** គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទមានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ,៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

ដើមចោទបានរៀបការជាមួយចុងចម្លើយជាប្តីប្រពន្ធតាំងពីឆ្នាំ២០០១ មកម្លេះតាមប្រពៃណី និង មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ទេ។ចាប់តាំងពីពេលរៀបការរួចមកជាមួយចុងចម្លើយ កូនពីរនាក់ឈ្មោះ[redacted] **ជូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ[redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ ២០០៧ ហើយខ្លួនសុំគ្រប់គ្រង

ជាអំណាចមេបាដោយមិនទាមទារអាហាកាតព្វកិច្ចចិញ្ចឹមកូនពីចុងចម្លើយទេ,៣.ទ្រព្យសម្បត្តិរួមមានដីទំហំ ៨ម គុណ ១២ម សង់លើដីកេរ្តិ៍ម្តាយដើមចោទ មានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ធ្វើនៅឆ្នាំ ២០១៣ នាងខ្ញុំសុំគ្រប់គ្រងព្រោះនាងខ្ញុំជាអ្នករកចំណូល និង ចំណាយតែម្នាក់ឯង ដោយភាគីចុងចម្លើយមិនបាន ចេញចំណាយអ្វីទាំងអស់ ការធ្វើផ្ទះនោះគឺនាងខ្ញុំជួលជាងជាចុងចម្លើយមកធ្វើផ្ទះ ហើយនាងខ្ញុំបានឱ្យលុយគាត់៣ ម៉ឺនរៀល ក្នុងមួយថ្ងៃសម្រាប់ជួលចុងចម្លើយជាលុយរបស់នាងខ្ញុំតែម្នាក់ឯក មិនមែនជាលុយរបស់គាត់ទេ ចុងចម្លើយតែងតែលេងល្បែងបំផ្លាញទ្រព្យសម្បត្តិអស់យ៉ាងច្រើន និងមានបំណងដុតផ្ទះចោលនិង មានជំពាក់បំណុលធនាគារចំនួន ៣២០០០$ (បីម៉ឺនពីរពាន់) ដុល្លាអាមេរិក នាងខ្ញុំសុំទទួលខុសត្រូវម្នាក់ឯង ។

មូលហេតុដែលខ្លួន ដាក់ពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយនេះ គឺដោយសារតែរស់នៅជាមួយគ្នាជាប្តីប្រពន្ធចេះឈ្លោះប្រកែកគ្នា ជាញឹកញាប់ធ្វើឱ្យគ្រួសារមិនមានសុភមង្គល ហើយនាងខ្ញុំនិងចុងចម្លើយរស់នៅមិននិយាយរកគ្នានោះទេ ហើយចុងចម្លើយមិនដែលផ្គត់ផ្គង់ចិញ្ចឹមនាងកូន និងគ្រួសារនោះទេ ធ្វើឱ្យនាងខ្ញុំអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធតទៅទៀត ទើបនាងខ្ញុំឱ្យតុលាការសម្រេចចេញសាលក្រមប្តឹងសុំផ្តាច់អនីតិសង្វាស់ពីប្តីដូចខាងលើ ។ សេចក្តីថ្លែងការខាងលើនេះ គប្បីតុលាការពិចារណា ផ្អែកលើភស្តុតាងជាក់ស្តែង ។

**-យល់ឃើញថា** ចុងចម្លើយបានធ្វើសេចក្តីថ្លែការណ៍តបថា ចំពោះការប្តឹងសុំផ្តាច់អនីតិសង្វាស់របស់ដើមចោទនោះ ខ្ញុំបាទមិនឯកភាពព្រមតាមការសុំរបស់ដើមចោទទេ។ ព្រោះកន្លងមកខ្ញុំបាទមិនមានកំហុសទេ, ចំពោះការសុំគ្រប់គ្រងកូនពីរនាក់ឈ្មោះ[redacted]**ជួរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ[redacted] **ច័ន្ទបរមុី** ភេទស្រី កើតឆ្នាំ២០០៧ មិនអាហាកាតព្វកិច្ច ព្រោះខ្ញុំបាទសុំគ្រប់គ្រងកូនដែរ,៣.ទ្រព្យសម្បត្តិរួមមានដីទំហំ **៨ម** គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទមានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ខ្ញុំបាទមិនឯកភាពតាមដើមចោទគឺខ្ញុំបាទសុំគ្រប់គ្រងដែរសុំបែងចែកជាពីរចំណែកស្មើគ្នាព្រោះ ជាកម្លាំងញើញឈាមដែលខ្ញុំបាទខិតខំបានធ្វើដោយផ្ទាល់ខ្លួនខ្លួនទទួលស្គាល់ថាដីដែលសង់ផ្ទះនោះម្តាយក្មេងនោះពិតប្រាកដមែន និងចំពោះបំណុលខ្ញុំបាទទទួលស្គាល់ថា មានជំពាក់គេ ចំនួន៣២០០០$ (បីម៉ឺនពីរពាន់) ជំពាក់ធនាគារអេស៊ីលីដាមានជំពាក់គ្នាបីនាក់ គឺសុំឱ្យតុលាការស្មើគ្នា ។ ការអះអាងខាងលើ នេះគប្បីតុលាការពិចារណាផ្អែកលើស្ថានភាពជាក់ស្តែង ។

**-យល់ឃើញថា** ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមានការជំពាក់ធានគារចំនួន ៣២០០០$ (បីម៉ឺនពីរពាន់) ជំពាក់ធនាគារអេស៊ីលីដា ដោយយកលុយធ្វើផ្ទះនេះអស់ហើយនាងខ្ញុំមិនទាមទារឱ្យចុងចម្លើយជួយចេញឡើយ គឺខ្លួនសុំគ្រប់គ្រងផ្ទះនេះតែម្នាក់ និងទទួលខុសត្រូវលើបំណុលតែម្នាក់ឯង ចំពោះការសុំគ្រប់គ្រងកូនទាំងពីរនាក់ និងសុំឱ្យតុលាការសម្រេចតាមការស្នើសុំខាងលើ ការអះអាងនេះគប្បីតុលាការពិចារណា។

**-យល់ឃើញថា** តាមសេចក្តីថ្លែការណ៍របស់ចុងចម្លើយថា ខ្លួនទទួលស្គាល់ថា មានការជំពាក់ធនាគារអេស៊ីលីដា ចំនួន៣២០០០$ (បីម៉ឺនពីរពាន់) ដូចការអះអាងរបស់ខ្លួនពិតប្រាកដមែន គប្បីតុលាការពិចារណា ។

**-យល់ឃើញថា** ចំពោះទ្រព្យសម្បត្តិរួមផ្ទះថ្ម ទំហំ **៨ម** គុណ **១២ម** សង់លើដីកេរ្តិ៍ម្តាយដើមចោទមានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ភាគីដើមចោទថា ខ្លួនជាអ្នកចេញលក់ធ្វើទាំងអស់ ចំណែក

ចុងចម្លើយមិនមានលុយជួយចេញធ្វើនោះទេគឺ គ្រាន់តែខ្លួនបានជួលឱ្យធ្វើផ្ទះតែប៉ុណ្ណោះសុំគ្រប់គ្រងតែម្នាក់ និង ទទួលខុសត្រូវលើបំណុល ជំពាក់ធនាគារអេស៊ីលីដា ចំនួន៣២០០០$(បីម៉ឺនពីរពាន់) តែម្នាក់ឯង ហើយចុងចម្លើយ អះអាង តបថា មិនព្រមតាមការស្នើសុំរបស់ដើមចោទនោះទេ ព្រោះផ្ទះនេះខ្លួនជាធ្វើចេញកម្លាំងញើញឈាមរបស់ ខ្លួនផ្ទាល់ដែរមិនព្រមឱ្យដើមចោទគ្រប់ គ្រងម្នាក់ឯងនោះទេ គឺខ្លួនសុំបែងចែកជាពីរចំណែកស្មើគ្នា ។ ដោយសារតែ ភាគីមានចំណុចវិវាទលើការបែងចែកទ្រព្យសម្បត្តិរួម និងបំណុលរួម ហេតុដូច្នេះ គប្បីតុលាការសម្រេចផ្អែកលើ ឆន្ទានុសិទ្ធិ និងតាមច្បាប់ ។

**-យល់ឃើញថា** ចំពោះការសុំគ្រប់គ្រងកូនពីរនាក់ឈ្មោះ [redacted] **ផូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] **ច័ន្ទបរម៉ី** ភេទស្រី កើតឆ្នាំ២០០៧ មិនអាហាកាតព្វកិច្ចរបស់ដើមចោទ ចុងចម្លើយមិនឯកភាព តែក្រោយពីតុលា ការសាកសួរទៅលើកូនទាំងពីរនាក់បានឆ្លើយថា ចង់ទៅរស់នៅជាមួយដើមចោទ ការស្នើសុំរបស់កូនទាំងពីរខាង លើនេះគប្បីតុលាការសម្រេចប្រគល់ឱ្យភាគីដើមចោទជាម្ដាយ ជាអ្នកមានអំណាចមេបាតាមការសម្រេចចិត្តរបស់ កូនៗទាំងពីរ។

**-យល់ឃើញថា** ចំពោះទ្រព្យសម្បត្តិរួមផ្ទះថ្មទំហំ៨ម គុណ **១២ម** សង់លើដីកេរ្តិ៍ម្ដាយដើមចោទមានទីតាំង នៅភូមិថ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ជាផ្ទះថ្មមិនអាចបែងចែកជាពីរចំណែកបានទេ ហើយភាគីដើម ចោទ និងចុងចម្លើយមិនឯកភាពក្នុងបែងចែកនោះឡើយ ។ ហេតុដូច្នេះតុលាការសម្រេចប្រគល់ទៅផ្ទះនេះរបស់ភា គីដើមចោទ និងចុងចម្លើយ ឱ្យទៅកូនឈ្មោះ [redacted] **ផូរអ័រ** ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] **ច័ន្ទបរម៉ី** ភេទស្រី កើតឆ្នាំ២០០៧ ជាពីរចំណែកស្មើគ្នា ។

**-យល់ឃើញថា** ចំពោះបំណុលរួម ដែលភាគីបានដាក់បង្ហាញតុលាការ ដែលភាគីអះអាងថា មានជំពាក់ ធនាគារអេស៊ីលីដាចំនួន៣២០០០$ (បីម៉ឺនពីរពាន់) ដុល្លាអាមេរិកនោះ ប្រគល់ឱ្យភាគីដើមចោទឈ្មោះ [redacted] **លក្ខិណា** ជាទទួលបន្ទុកសងម្នាក់ឯងតាមការព្រមព្រៀងរបស់សាមីខ្លួន ។

**-យល់ឃើញថា** គូភាគីពិតជាអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នា ហើយភាគីមិនអាចធ្វើការ ផ្សះផ្សាបានឡើយជាអនិតិសង្វាស់តទៅទៀតបានឡើយ ។ ដូចនេះភាគីដើមចោទ និង ចុងចម្លើយពិតអស់មនោស ញ្ចេតនាមិនអាចសះជារស់នៅជាអនីតិសង្វាស់ជាមួយគ្នាបន្តទៅទៀតបានឡើយ ហេតុដូច្នេះតុលាការគប្បីសម្រេច ទៅតាមសំណូមពរ របស់ដើមចោទសុំបញ្ឈប់ការរស់នៅជាអនីតិសង្វាស់ជាមួយគ្នាចាប់ពីពេលនេះតទៅ ។

**-យល់ឃើញថា** ដើមចោទ និង ចុងចម្លើយ បានរៀបការជាមួយគ្នាជាប្ដីប្រពន្ធតាមប្រពៃណី ដោយពុំមាន សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ គប្បីតុលាការពុំពិមិនពិចារណាលើការសុំលែងលះឡើយ ។

**-យល់ឃើញថា** ភាគីដើមចោទ និងចុងចម្លើយពុំបានឯកភាពលើការសុំផ្ដាច់ការរស់នៅជាអនិតិសង្វាស់នឹង គ្នាឡើយ,ចំណែកការបែងចែកទ្រព្យសម្បត្តិរួមភាគីទាំងពីរមិនមានការព្រមព្រៀងគ្នានោះទេ គប្បីតុលាការសម្រេច តាមឆន្ទានុសិទ្ធិ ។

**-យល់ឃើញថា** ប្រាក់ប្រដាប់ក្ដី តុលាការនឹងសម្រេចដោយផ្អែកលើបញ្ញត្តិដែលមានចែងក្នុង ក្រមនីតិវិធីរដ្ឋ ប្បវេណី ។

-យល់ឃើញថា ផ្អែកតាមការសំអាងហេតុខាងលើនេះ សាលាដំបូងខេត្តកំពង់ធំ សម្រេចចេញសាលក្រម ដែលមានខ្លឹមសារដូចតទៅ:

**សាលាដំបូងខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១- ឱ្យភាគីដើមចោទឈ្មោះ [redacted] លក្ខិណា និង ចុងចម្លើយឈ្មោះ [redacted] ប៊ុនផន បញ្ឈប់ការរស់នៅជាអនីតិសង្វាស់ជាមួយគ្នាចាប់ពីពេលនេះតទៅ ។

២- ឱ្យដើមចោទឈ្មោះ [redacted] លក្ខិណា ជាអ្នកមានអំណាចមេបាលើ កូនពីរនាក់ឈ្មោះ [redacted] ផូរអ័រ ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] ច័ន្ទបរម៉ី ភេទស្រី កើតឆ្នាំ២០០៧ ដោយមិនមានអាហាកាតព្វកិច្ចចិញ្ចឹមកូនពីចុងចម្លើយ។

៣- បែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម:

-ផ្ទះថ្មទំហំ៨ម គុណ ១២ម សង់លើដីកេរ្តិ៍ម្តាយដើមចោទមានទីតាំងនៅភូមិឃ្លៃ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ ប្រគល់ឱ្យទៅកូនឈ្មោះ [redacted] ផូរអ័រ ភេទស្រី កើតឆ្នាំ២០០៤ និងឈ្មោះ [redacted] ច័ន្ទបរម៉ី ភេទស្រី កើតឆ្នាំ២០០៧ចែកគ្នាជាពីរចំណែកស្មើគ្នា នៅពេលមាននីតិភាព ទុកជាអាការកាតព្វកិច្ច ។

៤- ឱ្យភាគីដើមចោទឈ្មោះ [redacted] លក្ខិណា ទទួលខុសត្រូវលើបំណុលតែម្នាក់ឯង ដែលជំពាក់ធនាគារ អេស៊ីលីដាចំនួន ៣២០០០$ (បីម៉ឺនពីរពាន់) ដុល្លាអាមេរិក តាមការព្រមព្រៀងរបស់សាមីខ្លួន ។

៥- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ តាមការព្រមព្រៀងរបស់សាមីខ្លួន ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ និង ប្រកាសសាលក្រមនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ ចាត់ទុកចំពោះភាគីដើមចោទ និង ចុងចម្លើយ ។

ទុកសិទ្ធិឱ្យភាគីប្តឹងឧទ្ធរណ៍ គិតចាប់ពីពេលភាគីទទួលដំណឹងអំពីអនុសារៈសាលក្រមនេះតទៅ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

.................................................................................................

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ១ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅកំពង់ធំ, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]